www.xtrapapers.com

M12/1/A1KHM/HP1/KHM/TZ0/XX

22120533

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A1 – HIGHER LEVEL – PAPER 1**
**KHMER A1 – NIVEAU SUPÉRIEUR – ÉPREUVE 1**
**KHMER A1 – NIVEL SUPERIOR – PRUEBA 1**

Thursday 10 May 2012 (morning)
Jeudi 10 mai 2012 (matin)
Jueves 10 de mayo de 2012 (mañana)

2 hours / 2 heures / 2 horas

---

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only.
- The maximum mark for this examination paper is *[25 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages.
- Le nombre maximum de points pour cette épreuve d'examen est *[25 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento.
- La puntuación máxima para esta prueba de examen es *[25 puntos]*.


© International Baccalaureate Organization 2012

*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

**១.**

## ពពកខ្មៅ

រូបលោកឯងមិនអាក្រក់ទេ ប៉ុន្តែចិត្តគំនិត និងសកម្មភាពរបស់លោកឯង អាក្រក់ជាទីបំផុតដូចពាក្យ លោកពោលថា "ចិត្តជាទេវទត្ត មាត់ជាទេវតា" កាលបើអ្នកណាសេពគប់ជាមួយ នឹងមានគ្រោះថ្នាក់ជាមិនខាន ។

ហ្សាក់គីមិនបានទទួលពាក្យថា "ស្រលាញ់" គឺថែមទាំងបានទទួលពាក្យបកអាក្រាតពីនាងដួងទៅវិញ ។

នាយប្រញាប់ធ្វើការដេញដោល :

- តើត្រង់ណា... ដែលនាងចោទថាខ្ញុំអាក្រក់នោះ ?

នាងដួងពេបមាត់សំដែងការពេបជ្រាយ :

- លោកឯងចាប់កូនក្រមុំអ្នកដទៃពីផ្ទះគេយកមកឃុំទុកនៅទីនេះល្មើសនឹងវិន័យច្បាប់ដូនតា គឺជាកំហុសទៅហើយ ហេតុអីក៏ឆ្លើយថាពុំដឹង ? លោកឯងដឹងថា តើឪពុកឬបងប្អូនគេមានការភ័យព្រួយពីវាសនាកូនចៅគេប៉ុណ្ណាទេ ? អំពើនេះធ្វើអោយក្នុងសង្គមមានការជ្រួលជ្រើមបាត់លំនឹងសតិអារម្មណ៍ដោយសារតែសកម្មភាពកំរោលនេះ ។

- តែបងមានឱ្យគេធ្វើបាបវាញដំ បង្អត់បាយ បង្អត់ទឹកដួងឯណា ? ដួងរស់នៅក្នុងបន្ទប់មួយយ៉ាងស្អាត មានអ្នកបំរើ មានរបស់ប្រើប្រាស់គ្រប់សព្វ តើមានអ្វីដែលធ្វើអោយដួងលំបាក ?

- ទេ ! ខ្ញុំមិនមែនជាសារិកាកែវ ជាលលក ជាជ្រូក ជាអ្នកទោសស្នេហ៍របស់អ្នកឯងឡើយ ។ ខ្ញុំជាសិក្ខាកាមដែលមានកាតព្វកិច្ចរៀន ខ្ញុំគ្មានពេលមកគិតល្បែងស្នេហាភ្លើតភ្លើនឆ្កួតៗរបស់លោកឯងទេ ! ដោះលែងខ្ញុំទៅ !

ហ្សាក់គីអស់សំណើចកក្អឹក :

- ហែស ហែស ហែស ! ដួចមិនមែនជាសារិកាកែវ ជាលលកមែន ប៉ុន្តែដួងជាអ្នកទោសស្នេហារបស់បង ។ តើដួងខំរៀនបានប្រយោជន៍អ្វី ? រៀនច្រើនត្រូវចំណាយពេលយូរឆ្នាំ បាត់បង់ការសប្បាយក្នុងវ័យក្មេងអស់ ។ ដូចបងនេះទំរាំដល់ចាស់គឺមានពេលសប្បាយច្រើនណាស់ ។ តាមបងឯនេះវិញ ។

- ខ្ញុំតាមឯងមិនបានទេ ការកើតមកជាមនុស្សដាច់ខាតត្រូវតែទទួលបានការសិក្សាអប់រំអោយបានច្រើន រៀនច្រើនចេះច្រើន ដឹងច្រើនគឺជាការល្អប្រពៃ ព្រោះគ្រប់ទង្វើរបស់គេសុទ្ធតែប្រកបដោយវិចារណញ្ញាណ និងគុណធម៌ ។ ផ្ទុយទៅវិញ មនុស្សអវិជ្ជាជាមនុស្សអន់ថយ ងងឹតងងុលធ្វើអ្វីៗគ្មានពិចារណារកហេតុផលវិជ្ជមាន ឬអវិជ្ជមានឡើយ ។

ហ្សាក់គីសើចសប្បាយទៀត ។ សំណើចចំអករលត់ នាយបដិសេធគំនិតដែលអះអាងដោយនាងដួង ហើយលើកឧទាហរណ៍:

- មិនពិត ! យើងឃើញអ្នករៀនមួយចំនួនចំណាយពេលតស៊ូរៀនសូត្ររហូតជ្រុះសក់ ទំពែកក្បាល ប៉ុន្តែគេមិនបានទទួលអ្វីអោយសមតាមចំណេះដែលគេមានសោះ គេនៅតែក្រ គេនៅតែនឿយលំបាកដដែល ។ ផ្ទុយទៅវិញ មានមួយចំនួនធំរៀនសូត្របន្តិចបន្តួច សរសេរអក្សរមិនត្រង់ជ្រុងត្រូវបែបបទផង គេមានទ្រព្យសម្បត្តិច្រើន មានខ្ញុំកំដរច្រើន មានលុយផ្ញើធនាគារ មានគេរាប់អានច្រើន ហើយគោរពកោតខ្លាចព្រោះ គេមានអំណាចទៀតផង ។ ដូចជារូបយើងនេះជាដើម យើងមិនដែលចូលសាលារៀនទេ ប៉ុន្តែយើងមានសញ្ញាប័ត្រ មានទ្រព្យសម្បត្តិ មានអំណាចហ៊ឺហា សម្បូរសប្បាយដែលអ្នករៀនសូត្រមួយចំនួនមិនអាចយកមកប្រៀបផ្ទឹមនឹងយើងបាន ។

នាងដួងគ្រវីក្បាល :

- តែទ្រព្យសម្បត្តិ និងអំណាចរបស់លោកមិនអាចស្ថិតស្ថេរនៅគង់វង្សបានយូរឡើយ ។ ទីបំផុត

ហ្វូ យ៉ាត, *ពពកខ្មៅ* (១៩៩៩)

www.xtrapapers.com



២.

## គ្មានន័យ

បើចេះប្រយ័ត្នប្រយោជន៍យូរយារ
ចេះស្រុះស្រួលគ្នាពិតជាក្សេមក្សាន្ត
ចេះយល់ចិត្តគិតប្រុងព្រមព្រៀងប្រាណ
ចេះបបួលបានទីឋានមូលមីរ ។
ចង្កឹះមួយបាច់គង់កាច់មិនបាក់
ជាផ្លុងស្មោះស្ម័គ្ររួបរួមសាមគ្គី
ចូរប្រិតប្រឹងប្រែងខ្នះខ្នែងសម្ដី
ជនក្សត់ញាំញីរវក់វីមិនកើត ។
អោយរឹងកុំទន់អោយធ្ងន់កុំស្រាល
គម្បីយល់កាលមើលរនោចខ្នើត
ខ្វចគឺបង្ការល្អគួរបង្កើត
សមលើកបណ្ដើតឆ្លងចេះរអើម ។
កុំទើសមុនទាស់កុំព្រោះមុនសាប
កុំហើរមុនស្លាបកុំជ្រាបមុនសើម
កុំបោះហួសចាប់ជាគ្រាប់ភ្លេចដើម
ឡើងទៅធ្លាក់ហើមចុះក្រោមដីទួល ។
កុំធ្មេចចាំភ្លឺកុំអ៊ឺក្រែងខ្សត់
កុំខ្ជិលភ្លាំងភ្លាំងកុំរត់ក្រែងដួល
កុំមើលនឹងភ្នែកកុំដេកចង់ស្រួល
កុំភ្លើនជ្រើមជ្រួលកុំមួលឬសដាច់ ។
កុំអួតកុំអញត្រីក្រាញ់ក្នុងអាង
កុំរលោមផ្លាងកុំតាំងចង់កាច់
កុំជាន់គ្នាឯងកុំថ្លែងបង្កាច់
កុំបានចាំបាច់កុំស្រេចតែខ្លួន ។
ធ្វើតាមស្រមោចធ្វើដូចកណ្ដៀរ
វាចេះជួយគ្នាការងារខ្ជាប់ខ្ជួន
វារួមសាមគ្គីមូលមីរមាំមួន
វាចេះថែធួនបងប្អូនក្នុងក្រុម ។
ឯយើងជាមនុស្សកុំខុសឆ្គងណា
យើងមានបញ្ញាអត្តាក៏ធំ
ត្រូវចេះស្រឡាញ់ក្រាញប្រមូលផ្ដុំ
ហើយគួរអប់រំកុំស្ដាយអញមក ។

ភិក្ខុ ប៉ុណ្ណ សុវណ្ណា, *គ្មានន័យ* (២០០៥)